ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ៖ ០១ "គ១" ក្រ.១១

ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ១៨០៩

ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ៖ ១៣៥៧

ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ៖៣៩៣៦

ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ០២ និង ៣០នាទី រសៀល នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក ជាចៅក្រុមប្រឹក្សា

លោកស្រី ជាចៅក្រុមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៨០៩ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] **ដាវី** ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិខ្មែរឥស្លាម មុខរបរលក់ដូរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ណាំ(ស្លាប់) ម្តាយឈ្មោះ [redacted] សុផាន(ស្លាប់) ប្តីឈ្មោះ [redacted] រ៉សេត មានកូនចំនួន ០២នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៖៣១១៥ "ឡ" .ដ.ឃ.ដ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ នៅមណ្ឌលអប់រំកែប្រែទី១( **ម១** )។

ជាប់ចោទពីបទ: **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខធនាគារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ **សមគំនិតក្នុងអំពើកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** និងបទ**សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិឃ សង្កាត់ច្រាំង ចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៩,មាត្រា៣៥៣,មាត្រា៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted] **រ៉សេត** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរឥស្លាម មុខរបរលក់ដូរ ទីកន្លែងកំណើតនៅ [redacted]

[redacted] ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះ[redacted] រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted]ដារី(រស់) មានកូនចំនួន០២នាក់ ឪពុកឈ្មោះ[redacted]សេន(រស់) ម្តាយឈ្មោះ[redacted]រី(រស់) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន:គ្មាន។(គេចខ្លួន)

ជាប់ចោទពីបទ:**លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខធនាគារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត និងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិយ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,មាត្រា៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មេធាវីឈ្មោះ[redacted]អត្តលេខ៖២៣២៥T ជាសមាជិកនៃគណៈមេធាវីកម្ពុជា និងជាសមាជិកនៃ **ការិយាល័យមេធាវីសាន់ ជួយ** មានអាសយដ្ឋាននៅផ្ទះលេខ១អា ផ្លូវលេខ២១២ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] **ដារី**។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]**សុភាព** ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទះសង់ថ្មី ផ្លូវបេតុង ភូមិកាកាប សង្កាត់កាកាបទី០២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ:</u>

-កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០៥ និង៣០នាទីទៀបភ្លឺ ជនជាប់ចោទមិនស្គាល់អត្តសញ្ញាណមានគ្នាចំនួនប្រហែល០៦នាក់ ជិះម៉ូតូចំនួន០៤គ្រឿង(ម៉ាកហុងដា សេ១២៥ និងម៉ាកស្កូពី) បានចេញធ្វើសកម្មភាពតាមបណ្តោយផ្លូវហាណូយ ដោយធ្វើដំណើរពីទិសខាងជើងមកខាងត្បូង លុះមកដល់ចំណុចធនាគារអេស៊ីលីដា ស្ថិតនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ក៏បានឃើញជនរងគ្រោះឈ្មោះ[redacted]សុភាព ភេទប្រុសអាយុ៣៩ឆ្នាំ ជនជាតិខ្មែរ ជិះម៉ូតូមួយគ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២០ ពាក់ផ្លាកលេខភ្នំពេញ១IL-៧៧៣៤ ដោយជិះតែម្នាក់ឯង ស្របទិសគ្នាភ្លាមនោះជនជាប់ចោទ ដែលជិះម៉ូតូម៉ាកសេ១២៥ តែម្នាក់ឯងបានជិះម៉ូតូមកអែបទន្ទឹមខាងឆ្វេងដៃជនរងគ្រោះ រួចធាក់ម៉ូតូជនរងគ្រោះបណ្តាលឱ្យជនរងគ្រោះដួលខ្ទាតចេញពីម៉ូតូ ពេលនោះបក្ខពួកជនជាប់ចោទបានឈប់ម៉ូតូរបស់ជនរងគ្រោះនាំគ្នាជិះគេចខ្លួនបាត់។ បន្ទាប់ពីកើតហេតុរួច ជនរងគ្រោះក៏បានប្តឹងសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលឃ្មួញ ក៏បានស្រាវជ្រាវតាមរយ:ជីភីអេស ដែលដាក់ជាប់ម៉ូតូរបស់ខ្លួន រហូតដល់ទីតាំងផ្ទះរបស់ជនជាប់ចោទឈ្មោះ[redacted]រ៉សេត ភេទប្រុស និងឈ្មោះ[redacted]ដារី ភេទស្រី ស្ថិតនៅផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិយ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ហើយសមត្ថកិច្ចក៏បានឆែកឆេររកឃើញវត្ថុតាងមួយចំនួនរួមមាន:១.អាវុធខ្លីម៉ាកK59 ចំនួន០១ដើម ពណ៌ទឹកប្រាក់ បង់ចំនួន០១គ្រាប់ ចំនួន០៧គ្រាប់,២.ក្រាមពណ៌សថ្លា សង្ស័យជាគ្រឿងញៀនចំនួន០៥កញ្ចប់,៣.កាតគ្រីម៉ូតូចំនួន០៦សន្លឹក និងសម្ភារ:ម៉ូតូមួយចំនួន,៤.ឧបករណ៍កែច្នៃគ្រឿងញៀនចំនួន០១សម្រាប់,៥.ម៉ូតូមួយគ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២០ ពាក់ស្លាកលេខភ្នំពេញ ១IL-៧៧៣៤ ជារបស់ជនរងគ្រោះ។ បន្ទាប់ពីឆែកឆេររកឃើញវត្ថុតាងខាងលើសមត្ថកិច្ចក៏នាំខ្លួនជនសង្ស័យឈ្មោះ អ៊ុង ដារី យកមកសាកសួរតែម្តង ចំណែកជនជាប់ចោទឈ្មោះ ឌា រ៉សេត បានរត់គេចខ្លួនបាត់។

-**បានឃើញ** របាយការណ៍សំយោគលេខ **០៦៤/២១ រ.ប.ក** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ១៣៨៨ អ.យ.ឆ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៣៦០១ អ.យ.ឆ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៩៩៥៩"ឡ" ដ.ដ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## **នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **ដារី** បានឆ្លើយថាៈខ្លួនបានរៀបការជាមួយឈ្មោះ [redacted] រ៉សេត នៅក្នុងឆ្នាំ២០១១ បានកូនចំនួន០២នាក់។ មួយរយៈពេលចុងក្រោយខ្លួន និងប្ដីឈ្មោះ [redacted] រ៉សេត បានរស់នៅមិនចុះសម្រុងនឹងគ្នា។ ផ្ទះរបស់ខ្លួនមានបន្ទប់នៅជាន់ផ្ទាល់ដីមាន០២បន្ទប់ និងជាន់ខាងលើមាន០២បន្ទប់។ខ្លួនដេកនៅបន្ទប់ជាន់លើទល់មុខបន្ទប់ក្មួយប្រុសថ្លៃឈ្មោះ [redacted] គីរីន។ប្តីខ្លួនឈ្មោះ [redacted] រ៉សេត ដេកនៅបន្ទប់ផ្ទាល់ដី។នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ពេលទៀបភ្លឺ ខ្លួនកំពុងចៀនសាច់គោទុកលក់ឱ្យម៉ូយ ក្មួយប្រុសថ្លៃរបស់ខ្លួននៅលើផ្ទះស្រាប់តែឃើញឈ្មោះ [redacted] មីន ភេទប្រុស អាយុប្រហែល២៥ឆ្នាំ មិនស្គាល់ទីលំនៅ បានជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ទុកនៅក្រោមផ្ទះ ឈ្មោះ [redacted] មីន បានដេកនៅលើអង្រឹងក្រោមផ្ទះ។ នៅវេលាថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ដដែល ពេលខ្លួនកំពុងតែចៀនសាច់គោនៅផ្ទះបាយស្រាប់តែឃើញប្តីខ្លួន និងឈ្មោះ [redacted] មីន បានស្ទុះរត់ចេញពីក្រោមផ្ទះ ទើបឃើញមានសមត្ថកិច្ចឆែកឆេរបន្ទប់ប្តីខ្លួនរកឃើញសម្ភារៈ និងអាវុធ,ម៉ូតូ សមត្ថកិច្ចបាននាំខ្លួននឹងក្មួយប្រុស [redacted] គីរីន ទៅអធិការដ្ឋាននគរបាលខណ្ឌសែនសុខ ហើយឃាត់ខ្លួនតែម្តង។ខ្លួនមិនបានដឹងនិងមិនបានចូលរួមក្នុងអំពើសមគំនិតជាមួយប្តីរបស់ខ្លួនទេ។ ខ្លួនមិនដែលបានចេញចូលបន្ទប់ប្តីរបស់ខ្លួនទេ ពីព្រោះខ្លួនជាមួយប្តីមិនសូវត្រូវគ្នា បន្ទប់ដែលខ្លួនដេក បានចេញចាក់សោរ-ចូលចាក់សោរ ជាប់រហូត។

-សាក្សីឈ្មោះ [redacted] **គីរីន** បានឆ្លើយថាៈខ្លួនត្រូវជាក្មួយរបស់ជនជាប់ចោទឈ្មោះ [redacted] ដារី។ សព្វថ្ងៃនេះជនជាប់ចោទឈ្មោះ [redacted] រ៉សេត និងជនជាប់ចោទឈ្មោះ [redacted] ដារី មិនសូវត្រូវគ្នាទេ ដោយគាត់ទាំងពីររស់នៅបន្ទប់ផ្សេងពីគ្នា ដោយជនជាប់ចោទឈ្មោះ [redacted] សេត នៅបន្ទប់ខាងក្រោមផ្ទះ និងជនជាប់ចោទឈ្មោះ [redacted] ដារី ជាមួយកូន នៅបន្ទប់ខាងលើផ្ទះ ទល់មុខបន្ទប់ខ្លួនដេក។ ខ្លួនបានរស់នៅជាមួយជនជាប់ចោទឈ្មោះ [redacted] ដារី ប្រហែលមួយឆ្នាំ ហើយខ្លួនមិនដែលឃើញជនជាប់ចោទឈ្មោះ [redacted] ដារី ចេញចូលបន្ទប់ប្តីរបស់គាត់នៅខាងក្រោមនោះទេ។នៅពេលព្រឹកសមត្ថកិច្ចមកដល់ផ្ទះរបស់ខ្លួន ពេលនោះពូថ្លៃរបស់ខ្លួនបានរត់គេចខ្លួនបាត់ ចំណែកខ្លួន និងឈ្មោះ [redacted] ដារី មិនបានរត់ទៅណាទេ ព្រោះកំពុងនៅចៀនសាច់គោ ទុកឱ្យម៉ូយ។

-សាក្សីឈ្មោះ [redacted] **លីដា** បានឆ្លើយថាៈជីវិតប្តីប្រពន្ធរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉សេត និងជនជាប់ចោទឈ្មោះ [redacted] ដារី មិនដែលត្រូវគ្នាទេ ហើយរស់នៅបែកបន្ទប់គ្នា។ជនជាប់ចោទឈ្មោះ [redacted] រ៉សេត គាត់មិនដែលសូវនៅផ្ទះទេ ហើយសព្វថ្ងៃរាល់បន្ទុកគ្រួសារគឺធ្លាក់ទៅលើ ជនជាប់ចោទឈ្មោះ [redacted] ដារី ជាអ្នករ៉ាប់រង។

-តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **សុភាព** បានឆ្លើយថាៈនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០៥ និង៣០នាទីព្រឹក មុនពេលកើតហេតុខ្លួនបានជិះម៉ូតូម៉ាកសេ១២៥ ស៊េរីឆ្នាំ២០២១ លេខតួ លេខម៉ាស៊ីន ពាក់ស្លាកលេខភ្នំពេញ១IL-៧៧៣៤(ជារបស់ខ្លួនផ្ទាល់) ចេញពីក្រុមហ៊ុនក្រឡុកបេតុង "ជីផាន"(សង្កាត់ស្វាយប៉ាក) ត្រឡប់ទៅផ្ទះស្នាក់នៅវិញ(សង្កាត់កាកាប២) ពេលធ្វើដំណើរតាមបណ្តោយផ្លូវភ្នំពេញហាណូយ ដល់ចំណុចមុខធនាគារអេស៊ីលីដា(ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ) ស្រាប់តែមានមនុស្សប្រុស(មិនស្គាល់អត្តសញ្ញាណ)ចំនួនប្រហែល០៦នាក់ ស្លៀកពាក់

ស៊ីវិលចម្រុះ អាយុប្រហែល១៨ឆ្នាំ ដល់២២ឆ្នាំ ជនជាតិខ្មែរ ជិះម៉ូតូចំនួន០៤គ្រឿង (ម៉ាកហុងដាសេ១២៥ និងម៉ាកស្កូបពី)ពីទិសខាងជើង មកទិសខាងត្បូង ស្របទិសគ្នាពីក្រោយ ពេលមកដល់ទន្ទឹមអែបខាងឆ្វេងដៃម៉ូតូរបស់ខ្លួន មានមនុស្សប្រុសម្នាក់ ជិះតែម្នាក់ឯង(ម៉ាកេ១២៥) លើកជើងធាក់ម៉ូតូរបស់ខ្លួន បណ្តាលឱ្យខ្លួនដួលខ្ទាតចេញពីលើម៉ូតូទៅលើចិញ្ចើមផ្លូវ ភ្លាមនោះជនជាប់ចោទបានឈប់ម៉ូតូ ចុះលើកម៉ូតូរបស់ខ្លួនគេចទៅបាត់។ បន្ទាប់មកខ្លួនដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ប៉ូលិស និងតាមដានជីភីអេស ខ្លួនបានចូលរួមជាមួយសមត្ថកិច្ច ហើយឃើញសញ្ញាណេតទីតាំងម៉ូតូរបស់ខ្លួនដែលបាត់ នៅម្តុំភូមិខ២ សង្កាត់ច្រាំងចំរេះទើបសមត្ថកិច្ចចុះទៅដល់ទីតាំងណេតគោលដៅម៉ូតូរបស់ខ្លួនធ្វើការឆែកឆេរ និងដកហូតម៉ូតូរបស់ខ្លួនបានមកវិញ ហើយខ្លួនបានដាក់ពាក្យបណ្តឹងចោទប្រកាន់លើម្ចាស់ផ្ទះតែម្តង។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា តាមភស្តុតាង លទ្ធផលសវនាការនៃការសួរដេញដោលបង្ហាញថាជនជាប់ចោទឈ្មោះ [redacted]រ៉សេត ពិតជាបានប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ,បទ**កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន សុំតម្កល់ការចោទប្រកាន់ និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]រ៉សេត ឱ្យបានធ្ងន់ និងប្តឹងសុំឱ្យសម្រេចអំពីការចាប់ខ្លួន តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះជនជាប់ចោទឈ្មោះ[redacted] ដាវី តំណាងអយ្យការយល់ឃើញថាពុំមានភស្តុតាងច្បាស់លាស់ គ្រប់គ្រាន់ថាជននេះបានប្រព្រឹត្តអំពើ **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា**,បទ**សមគំនិតក្នុងអំពើកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** និងបទ**សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដូចការចោទប្រកាន់នោះទេ តំណាងអយ្យការទុកសិទ្ធិជូនក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងពិចារណាសម្រេចតាមច្បាប់ចំពោះជនជាប់ចោទឈ្មោះ[redacted] ដាវី បើជនជាប់ចោទមិនបានប្រព្រឹត្តស្នើសុំសម្រេចឱ្យរួចខ្លួនពីបទចោទ តែបើយល់ថាមានភស្តុតាងថាបានប្រព្រឹត្តស្នើសុំឱ្យផ្តន្ទាទោសតាមច្បាប់។

## <u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ</u>

-មេធាវី [redacted]បានធ្វើសេចក្តីសន្និដ្ឋានថាកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ បើពិនិត្យទៅលើធាតុផ្សំបទល្មើស គឺមិនមានចូលទៅក្នុងធាតុផ្សំណាមួយឡើយ ដោយសារអវត្តមានមានអំពើប្រព្រឹត្ត ដែលជាធាតុផ្សំសំខាន់នៅក្នុងការកំណត់បទល្មើស។ ចៅក្រមស៊ើបសួរបានសម្រេចលើកលែងការចោទប្រកាន់ដល់ឈ្មោះ[redacted] គីរីន ដែលត្រូវជាក្មួយកូនក្តីរបស់ខ្លួន បានស្នាក់នៅបន្ទប់ទល់មុខនឹងបន្ទប់កូនក្តីរបស់ខ្លួនដែរ បន្ទាប់ពីពិនិត្យអង្គហេតុខាងលើ គឺឈ្មោះ[redacted] គីរីន និងឈ្មោះ[redacted] ដាវី មិនបានដឹង បានឮដូចគ្នា ដូច្នេះក្រុមប្រឹក្សាជំនុំជម្រះពិចារណា អំពីអង្គហេតុដែលចៅក្រមស៊ើបសួរបានពិនិត្យរួច។ កូនក្តីរបស់ខ្លួនជាប្រជាពលរដ្ឋល្អ ជាម្តាយដ៏ល្អ ប្រកបដោយសុចរិត ផ្គត់ផ្គង់គ្រួសារដែលត្រូវទទួលបន្ទុកអប់រំ និងចិញ្ចឹមបីបាច់កូន០២នាក់ ដោយសារឈ្មោះ[redacted]រ៉សេត ជាឪពុកមិនបានបំពេញតួនាទីល្អក្នុងនាមជាមេគ្រួសារ ទើបបន្ទុកទាំងអស់ធ្លាក់មកលើកូនក្តីខ្លួន។កថាខណ្ឌទី៦ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាវិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ បើពិនិត្យទៅលើភស្តុតាងដាក់បន្ទុកទៅលើកូនក្តីរបស់ខ្លួន គឺមិនមានភាពសមស្រប ហើយនៅមានចំណុចដែលជាផលប្រយោជន៍របស់កូនក្តីខ្លួនយ៉ាងច្រើន ដែលតុលាការគួរលើកយកមកពិចារណា និងសម្រេច កូនក្តីរបស់ខ្លួនបានសហការយ៉ាងល្អ នៅក្នុងការផ្តល់ចម្លើយតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ។ខ្លួនស្នើសុំឱ្យតុលាការពិនិត្យ និងសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីការចោទប្រកាន់ទាំងអស់ខាងលើ និងដោះលែងឱ្យកូនក្តីរបស់ខ្លួនឱ្យមានសេរីភាពឡើងវិញ។

## <u>សំដីចុងក្រោយរបស់ជនជាប់ចោទ</u>

-សម្ដីចុងក្រោយរបស់ជនជាប់ចោទបានស្នើសុំតុលាការមេត្តារកយុត្តិធម៌ដល់ខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ និងសុំឱ្យតុលាការមេត្តាឱ្យខ្លួនរួចផុតពីបទចោទ ពីព្រោះខ្លួនមានកូននៅក្នុងបន្ទុកត្រូវចិញ្ចឹមបីបាច់។

## <u>តុលាការ</u>

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១.ជនជាប់ចោទឈ្មោះ [redacted] **ដាវី** ភេទស្រី អាយុ៣៦ឆ្នាំ ត្រូវបានចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៦០១ **អ.យ.ឆ** ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៩៥៩"ឡ" ជ.ជ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ពីបទ **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខធនាគារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ **សមគំនិតក្នុងអំពើកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** និងបទ**សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តិនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិយ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៩,មាត្រា៣៥៣,មាត្រា៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។ ជនជាប់ចោទឈ្មោះ [redacted] **រ៉សេត** ដែលជាប់ចោទពីបទៈ**លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខធនា គារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត និងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិយ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២.អង្គហេតុនាំឱ្យមានការចោទប្រកាន់ឈ្មោះ [redacted] **ដាវី** គឺនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០៥ និង៣០នាទីព្រឹក មានជនមិនស្គាល់អត្តសញ្ញាណប្រហែល០៦នាក់ ជិះម៉ូតូចំនួន០៤គ្រឿង ជិះតាមបណ្ដោយផ្លូវភ្នំពេញហាណូយ ដល់ចំណុចមុខធនាគារអេស៊ីលីដាស្ថិតនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ បានធាក់ម៉ូតូជនរងគ្រោះឈ្មោះ [redacted] សុភាព ដែលធ្វើដំណើរតាមផ្លូវបណ្ដាលឱ្យជនរងគ្រោះដួលម៉ូតូហើយមានជនល្មើសម្នាក់បានម៉ូតូជនរងគ្រោះជិះគេចខ្លួន។ជនរងគ្រោះបានប្ដឹងដល់សមត្ថកិច្ចនគរបាលប៉ុស្ដិ៍សង្កាត់ឃ្មួញហើយសមត្ថកិច្ចបានស្រាវជ្រាវតាមរយៈជី



Scanned with CamScanner

ពិសេស ដែលជាប់ម៉ូតូជនរងគ្រោះនៅចំណុចទីតាំងផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉សេត ប្រពន្ធឈ្មោះ [redacted] ដារី នៅផ្ទះសង់ថ្មីផ្លូវជាតិលេខ៥ ភូមិឃ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានឆែកឆេរនិងចាប់យកវត្ថុតាងមួយចំនួនរួមមាន៖ អាវុធខ្លីម៉ាកK59 ពណ៌ទឹកប្រាក់ គ្មានលេខ បង់ចំនួន០១គ្រាប់ ចំនួន០៧គ្រាប់,ក្រាមពណ៌សថ្លា សង្ស័យជាគ្រឿងញៀនចំនួន០៥កញ្ចប់,កាតគ្រីម៉ូតូចំនួន០៦សន្លឹក និងសម្ភារៈម៉ូតូមួយចំនួន,ឧបករណ៍កែច្នៃជក់ថ្នាំញៀនចំនួន០១សម្រាប់(នៅក្នុងបន្ទប់ដេករបស់ជនជាប់ចោទឈ្មោះ [redacted] រ៉សេត),ម៉ូតូចំនួន០១គ្រឿង ម៉ាកសេរី១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០២០ ផ្លាកលេខភ្នំពេញ១IL-៧៧៣៤ ជារបស់ជនរងគ្រោះឈ្មោះ [redacted] សុភាពនៅចំហៀងបន្ទប់ដេករបស់ជនជាប់ចោទឈ្មោះ ខា រ៉សេត។ សមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] ដារី (ជាប្រពន្ធរបស់ឈ្មោះ [redacted] រ៉សេត) និងឈ្មោះ [redacted] គីរីន ភេទប្រុសត្រូវជាក្មួយបង្កើតរបស់ឈ្មោះ ខា រ៉សេត។ ចំពោះជនជាប់ចោទឈ្មោះ [redacted] រ៉សេត បានរត់គេចខ្លួននៅពេលសមត្ថកិច្ចចុះទៅដល់ផ្ទះ។

៣.ជនជាប់ចោទឈ្មោះ [redacted] **រ៉សេត** មិនមានចម្លើយដោះសារការពារខ្លួននៅគ្រប់ដំណាក់កាលដោយជនជាប់ចោទបានរត់គេចខ្លួននៅពេលសមត្ថកិច្ចចុះទៅដល់ផ្ទះ។

៤.ជនជាប់ចោទឈ្មោះ [redacted] **ដារី** បានឆ្លើយនៅគ្រប់ដំណាក់កាលប្រហាក់ប្រហែលគ្នាថា៖ ខ្លួនបានរៀបការជាមួយឈ្មោះ [redacted] រ៉សេត នៅក្នុងឆ្នាំ២០១១ បានកូនចំនួន០២នាក់។ មួយរយៈពេលចុងក្រោយខ្លួន និងប្តីឈ្មោះ [redacted] រ៉សេត បានរស់នៅមិនចុះសម្រុងនឹងគ្នា។ ផ្ទះរបស់ខ្លួនមានបន្ទប់ នៅជាន់ផ្ទាល់ដីមាន០២បន្ទប់ និងជាន់ខាងលើមាន០២បន្ទប់។ខ្លួនដេកនៅបន្ទប់ជាន់លើជាន់លើទល់មុខបន្ទប់ក្មួយប្រុសថ្លៃឈ្មោះ [redacted] គីរីន។ប្តីខ្លួនឈ្មោះ [redacted] រ៉សេត ដេកនៅបន្ទប់ផ្ទាល់ដី។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ពេលទៀបភ្លឺ ខ្លួនកំពុងចៀនសាច់គោទុកលក់ឱ្យម៉ូយ ក្មួយប្រុសថ្លៃរបស់ខ្លួននៅលើផ្ទះស្រាប់តែឃើញឈ្មោះ [redacted] មីន ភេទប្រុស អាយុប្រហែល២៥ឆ្នាំ មិនស្គាល់ទីលំនៅ បានជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ទុកនៅក្រោមផ្ទះ ឈ្មោះ [redacted] មីន បានដេកនៅលើអង្រឹងក្រោមផ្ទះ។ នៅវេលាថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ដដែល ពេលខ្លួនកំពុងតែចៀនសាច់គោនៅផ្ទះបាយស្រាប់តែឃើញប្តីខ្លួន និងឈ្មោះ [redacted] មីន បានស្ទុះរត់ចេញពីក្រោមផ្ទះ ទើបឃើញមានសមត្ថកិច្ចឆែកឆេរបន្ទប់ប្តីខ្លួនរកឃើញសម្ភារៈ និងអាវុធ,ម៉ូតូ សមត្ថកិច្ចបាននាំខ្លួននឹងក្មួយប្រុស [redacted] គីរីន ទៅអធិការដ្ឋាននគរបាលខណ្ឌសែនសុខ ហើយឃាត់ខ្លួនតែម្តង។ខ្លួនមិនបានដឹងនិងមិនបានចូលរួមក្នុងអំពើសមគំនិតជាមួយប្តីរបស់ខ្លួនទេ។ ខ្លួនមិនដែលបានចេញចូលបន្ទប់ប្តីរបស់ខ្លួនទេ ពីព្រោះខ្លួនជាមួយប្តីមិនសូវត្រូវគ្នា បន្ទប់ដែល [redacted] រ៉សេត ដេក បានចេញចាក់សោរ-ចូលចាក់សោរ ជាប់រហូត។ ចម្លើយរបស់ជនជាប់ចោទអាចឱ្យតុលាការជឿបាន ពីព្រោះជាចម្លើយដែលស៊ីសង្វាក់ទៅនឹងចម្លើយសាក្សីឈ្មោះ [redacted] គីរីន និងសាក្សីឈ្មោះ [redacted] លីដា ដែលបានឆ្លើយថាឈ្មោះ [redacted] ដារី និងប្តីឈ្មោះ [redacted] រ៉សេត រស់នៅមិនសូវត្រូវគ្នា នៅផ្ទះតែមួយ តែនៅបន្ទប់ផ្សេងគ្នា គឺឈ្មោះ [redacted] ដារី នៅបន្ទប់ជាន់លើ ឈ្មោះ [redacted] រ៉សេត នៅបន្ទប់ជាន់ក្រោម ហើយឈ្មោះ [redacted] ដារី មិនដែលចេញចូលបន្ទប់ឈ្មោះ [redacted] រ៉សេត នោះទេ ពីព្រោះឈ្មោះ [redacted] រ៉សេត បានចេញចាក់សោរ ចូលចាក់សោរជាប់រហូត។

៥.តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **សុភាព** បានឆ្លើយថា៖នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០៥ និង៣០នាទីព្រឹក មុនពេលកើតហេតុខ្លួនបានជិះម៉ូតូម៉ាកសេ១២៥ សេរីឆ្នាំ២០២១ លេខតួ លេខម៉ាស៊ីន ពាក់ស្លាកលេខភ្នំពេញ១IL-៧៧៣៤(ជារបស់ខ្លួនផ្ទាល់) ចេញពីក្រុមហ៊ុនក្រឡុកបេតុង "ជីធាន"(សង្កាត់ស្វាយប៉ាក) ត្រឡប់ទៅផ្ទះស្នាក់នៅវិញ(សង្កាត់កាកាប២) ពេលធ្វើដំណើរតាមបណ្តោយផ្លូវភ្នំពេញហាណូយ ដល់ចំណុចមុខធនាគារអេស៊ីលីដា(ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ) ស្រាប់តែមានមនុស្សប្រុស(មិនស្គាល់អត្តសញ្ញាណ)ចំនួនប្រហែល០៦នាក់ ស្លៀកពាក់ស៊ីវិលចម្រុះ អាយុប្រហែល១៨ឆ្នាំ ដល់២២ឆ្នាំ ជនជាតិខ្មែរ ជិះម៉ូតូចំនួន០៤គ្រឿង (ម៉ាកហុងដាសេ១២៥ និងម៉ាកស្គូបពី)ពី

ទិសខាងជើង មកទិសខាងត្បូង ស្របទិសគ្នាពីក្រោយ ពេលមកដល់ទន្ទឹមអែបខាងឆ្វេងដៃម៉ូតូរបស់ខ្លួន មានមនុស្សប្រុសម្នាក់ ជិះតែម្នាក់ឯង(ម៉ាកេ១២៥) លើកជើងធាក់ម៉ូតូរបស់ខ្លួន បណ្តាលឱ្យខ្លួនដួលខ្ទាតចេញពីលើម៉ូតូទៅលើចិញ្ចើមផ្លូវ ភ្លាមនោះជនជាប់ចោទបានឈប់ម៉ូតូ ចុះលើកម៉ូតូរបស់ខ្លួនគេចទៅបាត់។ បន្ទាប់មកខ្លួនដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ប៉ូលីស និងតាមដានជីភីអេស ខ្លួនបានចូលរួមជាមួយសមត្ថកិច្ច ហើយឃើញសញ្ញាណោតទីតាំងម៉ូតូរបស់ខ្លួនដែលបាត់ នៅម្តុំភូមិខ២ សង្កាត់ច្រាំងចំរេះទើបសមត្ថកិច្ចចុះទៅដល់ទីតាំងលោតគោលដៅម៉ូតូរបស់ខ្លួនធ្វើការឆែកឆេរ និងដកហូតម៉ូតូរបស់ខ្លួនបានមកវិញ ហើយខ្លួនបានដាក់ពាក្យបណ្តឹងចោទប្រកាន់លើម្ចាស់ផ្ទះតែម្តង។ តាមអំណានចម្លើយនេះ អាចបញ្ជាក់ថាជនជាប់ចោទឈ្មោះ ឌា វ៉សេត ពិតជាបានប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់មែន។

៦.សាក្សីឈ្មោះ [redacted] **គីរីន** បានឆ្លើយថា៖ខ្លួនត្រូវជាក្មួយរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉សេត។ សព្វថ្ងៃនេះជនជាប់ចោទឈ្មោះ [redacted] វ៉សេត និងជនជាប់ចោទឈ្មោះ [redacted] ដារី មិនសូវត្រូវគ្នាទេ ដោយគាត់ទាំងពីររស់នៅបន្ទប់ផ្សេងពីគ្នា ដោយជនជាប់ចោទឈ្មោះ [redacted] វ៉សេត នៅបន្ទប់ខាងក្រោមផ្ទះ និងជនជាប់ចោទឈ្មោះ [redacted] ដារី ជាមួយកូន នៅបន្ទប់ខាងលើផ្ទះ ទល់មុខបន្ទប់ខ្លួនដេក។ ខ្លួនបានរស់នៅជាមួយជនជាប់ចោទឈ្មោះ [redacted] ដារី ប្រហែលមួយឆ្នាំ ហើយខ្លួនមិនដែលឃើញជនជាប់ចោទឈ្មោះ [redacted] ដារី ចេញចូលបន្ទប់ប្តីរបស់គាត់នៅខាងក្រោមនោះទេ។នៅពេលព្រឹកសមត្ថកិច្ចមកដល់ផ្ទះរបស់ខ្លួន ពេលនោះពូថ្លៃរបស់ខ្លួនបានរត់គេចបាត ចំណែកខ្លួន និងឈ្មោះ [redacted] ដារី មិនបានរត់ទៅណាទេ ព្រោះកំពុងនៅចៀរសាច់គោ ទុកឱ្យម៉ូយ។ ចម្លើយរបស់សាក្សីមានភាពស៊ីសង្វាក់គ្នា ទៅនឹងចម្លើយរបស់ជនជាប់ចោទ [redacted] ដារី ដែលអាចឱ្យតុលាការអាចជឿបាន។

៧.ឈ្មោះ [redacted] **លីដា** បានឆ្លើយជាសាក្សីនាពេលសវនាការថា:ឈ្មោះ [redacted] ដារី និងប្តីឈ្មោះ [redacted] វ៉សេត រស់នៅជាមួយគ្នាមិនសូវត្រូវគ្នាទេ នៅផ្ទះតែមួយ តែបន្ទប់ផ្សេងគ្នា។ ឈ្មោះ [redacted] ដារី នៅបន្ទប់ជាន់លើ ចំណែកឈ្មោះ [redacted] វ៉សេត នៅបន្ទប់ជាន់ក្រោម។ ខ្លួនបានដឹងថា បន្ទប់ដែលឈ្មោះ [redacted] វ៉សេត នៅជាន់ក្រោម ចេញចាក់សោរ ចូលចាក់សោរ ហើយឈ្មោះ [redacted] ដារីមិនដែលចេញចូលបានទេ។ ចម្លើយរបស់សាក្សីអាចឱ្យតុលាការយកមកពិចារណាបានពីព្រោះចម្លើយស៊ីសង្វាក់ ទៅនឹងចម្លើយសាក្សីឈ្មោះ [redacted] គីរីន ផងដែរ។

៨.តាមចម្លើយរបស់ជនរងគ្រោះថាពេលក្រុមជនល្មើសធ្វើសកម្មភាពធាក់ម៉ូតូរបស់ខ្លួនឱ្យដួលរួចយកម៉ូតូនោះ ជាមនុស្សប្រុសប្រហែល “០៦នាក់” ដោយពុំមានមនុស្សស្រីនោះទេ ចំណុចនេះអាចឱ្យតុលាការពិចារណាបាន ចំពោះការចោទប្រកាន់ឈ្មោះ [redacted] ដារី ភេទស្រី ថាបានចូលរួមសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ដែលចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនមកជំនុំជម្រះ គឺជនជាប់ចោទឈ្មោះ [redacted] ដារី គ្មានវត្តមាននៅកន្លែងប្រព្រឹត្តបទល្មើសដែលក្រុមជនល្មើសជាមនុស្សប្រុសចំនួន០៦នាក់នោះទេ។

៩.ការដែលចៅក្រមស៊ើបសួរដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និងចោទប្រកាន់ឈ្មោះ [redacted] **ដារី** ភេទស្រី បញ្ជូនមកជំនុំជម្រះពីបទសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខធនាគារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ សមគំនិតក្នុងអំពើកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត និងបទសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិឃ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់នោះឡើយគឺការចោទប្រកាន់ជាលក្ខណៈវិមតិសង្ស័យដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ស្របតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១០.តាមស្មារតីមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីវិមតិសង្ស័យត្រូវតែបាន



Scanned with CamScanner

ជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

១១.តាមស្មារតីមាត្រា២៩(និយមន័យអ្នកសមគំនិត)កថាខណ្ឌទី១នៃក្រមព្រហ្មទណ្ឌចែងថា:ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយផ្ដល់ជំនួយឬការឧបត្ថម្ភរបស់ខ្លួន។ ចំពោះជនជាប់ចោទឈ្មោះ [redacted] ដារី ពុំមានភស្តុតាងបញ្ជាក់ថាខ្លួនបានជួយដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ដល់ជំនួយ ឬឧបត្ថម្ភរបស់ខ្លួនឱ្យឈ្មោះ [redacted] រ៉សេត ជាប្ដីប្រព្រឹត្តបទល្មើសនោះទេ។តាមគោលការណ៍ច្បាប់ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្តតែប៉ុណ្ណោះ មិនអាចកំណត់ថាប្ដីប្រព្រឹត្តប្រពន្ធត្រូវតែចូលរួមសមគំនិតនោះទេ។

១២.តាមធាតុផ្សំនៃអំពើសមគំនិតជាសត្យានុម័ត ជនជាប់ចោទឈ្មោះ [redacted] ដារី មិនបានផ្ដល់ជាមធ្យោបាយដូចជាការផ្ដល់អាវុធ ការផ្ដល់ឧបករណ៍ ឬមធ្យោបាយផ្សេងទៀតដែលអាចយកទៅប្រើប្រាស់ ដើម្បីបំពេញសកម្មភាពបទល្មើសនោះទេ។លើសពីនេះទៅទៀតទំនាក់ទំនងប្ដីប្រពន្ធរបស់ជនជាប់ចោទទាំងពីរ មិនមានលក្ខណៈល្អប្រសើរនោះទេ ព្រោះជនជាប់ឈ្មោះ [redacted] រ៉សេត បានរស់នៅបន្ទប់ជាន់ក្រោមផ្ទះ និងជនជាប់ចោទឈ្មោះ [redacted] ដារី បានរស់នៅបន្ទប់ខាងលើផ្ទះជាមួយកូនទាំងពីរនាក់ ហើយជនជាប់ចោទឈ្មោះ [redacted] ដារី មិនដែលបានចូលបន្ទប់ប្ដីរបស់ខ្លួននោះទេ ដោយហេតុថាបន្ទប់ដែលប្ដីខ្លួនដេក បានចេញចាក់សោរ-ចូលចាក់សោរ ជាប់រហូត។យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដារី អាចបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ដារី មិនបានផ្ដល់ជំនួយ ឬការឧបត្ថម្ភផ្នែកស្មារតីដល់ជនជាប់ចោទឈ្មោះ [redacted] សេត ឱ្យសម្រេចបាននូវបទល្មើស និងមិនបានដឹងការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉សេត នោះទេ។

១៣.ធាតុផ្សំនៃអំពើសមគំនិតជាអត្តនាម័ត របស់ជនជាប់ចោទឈ្មោះ [redacted] ដារី មិនមានចេតនាទុច្ចរិតក្នុងការជម្រុញ ឬបង្កឱ្យបទល្មើសកើតឡើងនោះទេ ព្រោះជនជាប់ចោទឈ្មោះ [redacted] ដារី មិនបានដឹងអំពីការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ ឌា រ៉សេត នោះឡើយ។

១៤.តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] សុភាព តាមរយៈភស្តុតាងចាប់យកម៉ូតូជនរងគ្រោះរកឃើញដោយមានភ្ជាប់ប្រព័ន្ធជីភីអេស នៅផ្ទះឈ្មោះ [redacted] រ៉សេត វត្ថុចាប់យកជាអាវុធ ជាថ្នាំញៀន និងសម្ភារៈផ្សេងៗទៀត ព្រមទាំងចម្លើយរបស់សាក្សីឈ្មោះ [redacted] ដារី, ចម្លើយរបស់សាក្សីឈ្មោះ [redacted] គីរីន និងការរត់គេចខ្លួនរបស់ជនជាប់ចោទឈ្មោះ ឌា រ៉សេត បានបញ្ជាក់ឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] រ៉សេត ពិតជាបានប្រព្រឹត្តបទល្មើសច្រើនបទ ដូចដែលចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះ ប្រាកដមែន ដោយមានភស្តុតាងលើសពីវិមតិសង្ស័យ។

១៥.តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនលេខ៦៤/២១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ ដែលបានធ្វើតេស្តលើជនជាប់ចោទឈ្មោះ [redacted] ដារី ភេទស្រី ដែលធ្វើតេស្តប្រភេទ One Test Strip (តេស្តរហ័សសម្រាប់ស្វែងរកសាធាតុញៀន ប្រភេទមេតំហ្វេតាមីន ក្នុងទឹកនោម) ដោយធ្វើតេស្តនៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ដារី ជាលទ្ធផល អវិជ្ជមាន មានន័យថាគ្មានសារធាតុញៀន។តាមរយៈកំណត់ហេតុនេះ និងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ដារី ដែលបានឆ្លើយនាពេលសវនាការ បញ្ជាក់ថាជនជាប់ពិតមិនចេះប្រើប្រាស់ថ្នាំញៀន និងមិនបានចូលរួមសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

១៦.តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៣២៣២៨/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបង្ហាញថា សំណាកជាប្រភេទក្រាមម្សៅថ្លា ពណ៌សទម្ងន់០,៦៨៧៩ ក្រាម ដែលមានលទ្ធផលវិជ្ជមាន មានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ



Scanned with CamScanner

៧៨.៤៩ភាគរយ។យោងតាមកំណត់ហេតុទទួលស្គាល់ភស្តុតាង របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខលេខ៦៤/២១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ថ្នាំញៀននេះត្រូវបានឆែកឆេរឃើញនៅក្នុងបន្ទប់ដេករបស់ជនជាប់ចោទឈ្មោះ [redacted]រ៉េសេត មានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ ដែលបញ្ជាក់បានជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ពិតប្រាកដមែន។

១៧.តាមកំណត់ហេតុទទួលស្គាល់ភស្តុតាងចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ ដែលដកហូតបានអាវុធខ្លីម៉ាកK59 ចំនួន០១ដើម ពណ៌ទឹកប្រាក់ បង់ចំនួន០១គ្រាប់ ចំនួន០៧គ្រាប់,ក្រាមពណ៌សថ្លាសង្ស័យជាគ្រឿងញៀនចំនួន០៥កញ្ចប់, កាតគ្រីម៉ូតូចំនួន០៦សន្លឹក និងសម្ភារៈម៉ូតូមួយចំនួន, ឧបករណ៍កែច្នៃគ្រឿងញៀនចំនួន០១សម្រាប់ គឺដកហូតបានក្នុងបន្ទប់របស់ជនជាប់ចោទឈ្មោះ ឌា រ៉េសេត ដោយឡែកម៉ូតូមួយគ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២០ ពាក់ស្លាកលេខភ្នំពេញ ១IL-៧៧៣៤ គឺឈ្មោះ លី មីន បានជិះម៉ូតូយកមកទុក។ តាមរយៈភស្តុតាងដែលដកហូតបាន និងតាមអង្គហេតុពិតជាមានភាពស៊ីសង្វាក់គ្នាដែលដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted]រ៉េសេត ពិតជាបានប្រព្រឹត្តបទល្មើសពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិឃ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,មាត្រា ៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៨.តាមកំណត់ហេតុទទួលស្គាល់ភស្តុតាងចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ បញ្ជាក់ថាគឺឆែកឆេរឃើញនៅក្នុងបន្ទប់របស់ជនជាប់ចោទឈ្មោះ [redacted] រ៉េសេត។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ដាវី ដែលបានឆ្លើយថា ខ្លួនមិនដែលបានចេញចូលបន្ទប់ប្តីរបស់ខ្លួនទេ ពីព្រោះខ្លួនជាមួយប្តីមិនសូវត្រូវគ្នា បន្ទប់ដែលខ្លួនដេក បានចេញចាក់សោរ-ចូលចាក់សោរ មានភាពស៊ីសង្វាក់គ្នាដែលបញ្ជាក់ថាឈ្មោះ [redacted] ដាវី មិនមានទំនាក់ទំនងល្អរវាងជនជាប់ចោទឈ្មោះ [redacted] រ៉េសេត ដោយគ្រាន់តែរស់នៅក្រោមដំបូលផ្ទះតែមួយ។ តែចំពោះសកម្មភាពបទល្មើសដែលជនជាប់ចោទឈ្មោះ [redacted] រ៉េសេត ខ្លួនមិនបានដឹងនិងមិនបានចូលរួមក្នុងអំពើសមគំនិតជាមួយប្តីរបស់ខ្លួនទេ។

១៩.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted]**រ៉េសេត** ដែលបានធ្វើសកម្មភាពផាក់ផ្តួលម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] **សុភាព** ហើយបានយកម៉ូតូរបស់ជនរងគ្រោះគឺជាបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២០.ការកាន់កាប់អាវុធរបស់ជនជាប់ចោទឈ្មោះ [redacted]**រ៉េសេត** ដោយគ្មានការអនុញ្ញាត្តិពីអាជ្ញាធរមានសមត្ថកិច្ច ជាបទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ។

២១.ជនជាប់ចោទឈ្មោះ [redacted] **រ៉េសេត** ជានីតិជន ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជនជាប់ចោទអាចយល់ដឹងបានអំពើផលវិបាកដែលខ្លួនបានប្រព្រឹត្ត តែជនជាប់ចោទនៅតែប្រព្រឹត្តដោយចេតនា។

២២.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **រ៉េសេត** បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ដែលត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើសដែលត្រូវផ្តន្ទាទោស។

២៣.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមភស្តុតាង លទ្ធផលសវនាការនៃការសួរដេញដោលបង្ហាញថាជនជាប់ចោទឈ្មោះ [redacted]**សេត** ពិតជាបានប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ,បទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត និងជួញដូរដោយខុសច្បាប់នូវសារ**



Scanned with CamScanner

ធាតុញៀន ពិតប្រាកដមែន សុំតម្កល់ការចោទប្រកាន់ និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]រ៉ី សេត ឱ្យបានធ្ងន់ និងប្តឹងសុំឱ្យសម្រេចអំពីការចាប់ខ្លួន តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] ដារី តំណាងអយ្យការយល់ឃើញថាពុំមានភស្តុតាងច្បាស់លាស់ គ្រប់គ្រាន់ថាជននេះបានប្រព្រឹត្តអំពើ**សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា**,បទ**សមគំនិតក្នុងអំពើកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** និងបទ**សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដូចការចោទប្រកាន់នោះទេ តំណាងអយ្យការទុកជូនក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងពិចារណាសម្រេចតាមច្បាប់ចំពោះជនជាប់ចោទឈ្មោះ [redacted] ដារី បើជនជាប់ចោទមិនបានប្រព្រឹត្តស្នើសុំសម្រេចឱ្យរួចខ្លួនពីបទចោទ តែបើយល់ថាមានភស្តុតាងថាបានប្រព្រឹត្តស្នើសុំឱ្យផ្តន្ទាទោសតាមច្បាប់។ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការត្រឹមត្រូវតាមអង្គហេតុ និងភស្តុតាង តុលាការទទួលមកពិចារណា។

២៤.មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថាកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ បើពិនិត្យទៅលើធាតុផ្សំបទល្មើស គឺមិនមានចូលទៅក្នុងធាតុផ្សំណាមួយឡើយ ដោយសារអវត្តមានមានអំពើប្រព្រឹត្ត ដែលជាធាតុផ្សំសំខាន់នៅក្នុងការកំណត់បទល្មើស។ ចៅក្រមស៊ើបសួរបានសម្រេចលើកលែងការចោទប្រកាន់ដល់ឈ្មោះ [redacted] គីរីន ដែលត្រូវជាក្មួយកូនក្តីរបស់ខ្លួន បានស្នាក់នៅបន្ទប់ទល់មុខនឹងបន្ទប់កូនក្តីរបស់ខ្លួនដែរ បន្ទាប់ពីពិនិត្យអង្គហេតុខាងលើ គឺឈ្មោះ [redacted] គីរីន និងឈ្មោះ [redacted] ដារី មិនបានដឹង បានឮដូចគ្នា ដូច្នេះក្រុមប្រឹក្សាជំនុំជម្រះពិចារណា អំពីអង្គហេតុដែលចៅក្រមស៊ើបសួរបានពិនិត្យរួច។ កូនរបស់ខ្លួនជាប្រជាពលរដ្ឋល្អ ជាម្តាយដ៏ល្អ ប្រកបដោយសុចរិត ផ្គត់ផ្គង់គ្រួសារដែលត្រូវទទួលបន្ទុកអប់រំ និងចិញ្ចឹមបីបាច់កូន០២នាក់ ដោយសារឈ្មោះ [redacted]សេត ជាឪពុកមិនបានបំពេញតួនាទីល្អក្នុងនាមជាមេគ្រួសារ ទើបបន្ទុកទាំងអស់ធ្លាក់មកលើកូនក្តីខ្លួន។ កថាខណ្ឌទី៦ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាវិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ បើពិនិត្យទៅលើភស្តុតាងដាក់បន្ទុកទៅលើកូនក្តីរបស់ខ្លួន គឺមិនមានភាពសមសមស្រប ហើយនៅមានចំណុចដែលជាផលប្រយោជន៍របស់កូនក្តីខ្លួនយ៉ាងច្រើន ដែលតុលាការគួរលើកយកមកពិចារណា និងសម្រេច កូនក្តីរបស់ខ្លួនបានសហការយ៉ាងល្អ នៅក្នុងការផ្តល់ចម្លើយតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ។ខ្លួនស្នើសុំឱ្យតុលាការពិនិត្យ និងសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីការចោទប្រកាន់ទាំងអស់ខាងលើ និងដោះលែងឱ្យកូនក្តីរបស់ខ្លួនឱ្យមានសេរីភាពឡើងវិញ។ ការសន្និដ្ឋាននេះត្រឹមត្រូវស្របតាមច្បាប់ គប្បីតុលាការយកពិចារណា។

២៥.គ្មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ដារី** ភេទស្រី អាយុ៣៦ឆ្នាំ ពីបទ **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខធនាគារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ **សមគំនិតក្នុងអំពើកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** និងបទ**សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិឃ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៩,មាត្រា៣៥៣,មាត្រា៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នោះទេ តុលាការត្រូវសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted]ដារី រួចខ្លួនពីបទចោទស្របតាមមាត្រា៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២៦.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ [redacted]រ៉ៃសេត ភេទប្រុស អាយុ៣៧ឆ្នាំ ពីបទ ៖**លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខធនាគារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តិនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិយ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,មាត្រា៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ តុលាការត្រូវប្រកាសផ្តន្ទាទោសជនជាប់ចោទឈ្មោះ ឌា រ៉ៃសេត តាមច្បាប់បញ្ញត្តិស្របតាមមាត្រា៣៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២៧.ជនជាប់ចោទឈ្មោះ[redacted]រ៉ៃសេត បានប្រព្រឹត្តបទល្មើសច្រើនបទត្រួតគ្នាក្នុងអង្គហេតុដែលចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះ។ បទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តជាបទល្មើសធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គមយ៉ាងធ្ងន់ធ្ងរ តុលាការគប្បីផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]រ៉ៃសេត ឱ្យបានធ្ងន់ធ្ងរដោយផ្អែកទៅលើតាមបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ និងកាលៈទេសៈនៃបទល្មើសរបស់ជនជាប់ចោទតម្រូវ។

២៨.សម្តីចុងក្រោយរបស់ជនជាប់ចោទបានស្នើរសុំតុលាការមេត្តារកយុត្តិធម៌ដល់ខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ និងសុំឱ្យតុលាការមេត្តាឱ្យខ្លួនរួចផុតពីបទចោទ ព្រោះខ្លួនមានកូននៅក្នុងបន្ទុកត្រូវមើលថែ។ការស្នើសុំនេះមានភាពត្រឹមត្រូវស្របតាមច្បាប់គប្បីតុលាការយកមកពិចារណា។

២៩.អំពីវត្ថុចាប់យកមាន៖ អាវុធខ្លីម៉ាកកា៥៩ ពណ៌ទឹកប្រាក់ចំនួន០១ដើម បង់ចំនួន០១ គ្រាប់ចំនួន០៧គ្រាប់, ក្រាមពណ៌សថ្លា ជាគ្រឿងញៀនទម្ងន់១៧,៨២ក្រាម និងសំបកថង់ប្លាស្ទិចចំនួន៥ ,ប័ណ្ណសម្គាល់ទោចក្រយានយន្តកាតគ្រីម៉ូតូចំនួន០៦សន្លឹក និងសម្ភារៈម៉ូតូមួយចំនួន ជាភស្តុតាងពិតប្រាកដនៃបទល្មើស ដែលត្រូវរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>ហេតុដូច្នេះសម្រេច</u>

**១**.ឱ្យឈ្មោះ[redacted]**ដាវី** ភេទស្រី អាយុ៣៦ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) រួចខ្លួនពីបទចោទ:**សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខធនាគារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ **សមគំនិតក្នុងអំពើកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** បទ**សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសង់ថ្មី ផ្លូវជាតិលេខ៥ ភូមិយ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៩,មាត្រា៣៥៣,មាត្រា៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌនិងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២**.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]**រ៉ៃសេត** ភេទប្រុស អាយុ៣៧ឆ្នាំ (អត្តសញ្ញាណដូចខាងលើ)ដាក់ពន្ធនាគារ ០៧(ប្រាំពីរ)ឆ្នាំ។

ពីបទ:**លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខធនាគារអេស៊ីលីដា ផ្លូវភ្នំពេញហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសង់ថ្មី ផ្លូវ



Scanned with CamScanner

ជាតិលេខ៥ ភូមិឃ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,មាត្រា៣៥៧ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនពិរុទ្ធជនឈ្មោះ [redacted]**រ៉សេត** តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤.រឹបអូសវត្ថុចាប់យកៈអាវុធខ្លីម៉ាកកា៥៩ ពណ៌ទឹកប្រាក់ចំនួន០១ដើម បង់ចំនួន០១ គ្រាប់ចំនួន០៧គ្រាប់, ក្រាមពណ៌សថ្លា ជាគ្រឿងញៀនទម្ងន់១៧,៨២ក្រាម និងសំបកថង់ប្លាស្ទិចចំនួន៥ ,ប័ណ្ណសម្គាល់ទោចក្រយានយន្តកាតគ្រីម៉ូតូចំនួន០៦សន្លឹក និងសម្ភារៈម៉ូតូមួយចំនួន តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៥.សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ដាវី** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]**រ៉សេត**។

**ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។**

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ៍ ០២កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]